ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ៧ លេខ ៨៦ សប្តាហ៍ទី ៣ ថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០០៧

រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

តម្លៃជាវ

១ ច្បាប់	៥.០០០ រៀល
១ ខែ	៤០.០០០ រៀល
៣ ខែ	១២០.០០០ រៀល
៦ ខែ	២៤០.០០០ រៀល
១២ ខែ	៤៨០.០០០ រៀល

(ត្រូវបង់តម្លៃជាវជាមុន)

348.033
CAM

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសំរេច សារាចរ ប្រកាស

ក

មាតិកា

I.ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

១៥-១១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១១០៧/៥៧៨ ស្តីពីការតែងតាំងឯកឧត្តម **ខៀវ សារ៉ា** ជាទីប្រឹក្សាឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើអនុរដ្ឋលេខាធិការ ដោយមិនទទួលប្រាក់បៀវត្ស ៥៣០៤

១៥-១១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១១០៧/៥៧៩ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះលោកជំទាវ, ព្រះអង្គម្ចាស់ក្សត្រី និងឯកឧត្តម ចំនួន ០៣ រូប ៥៣០៥

១៥-១១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១១០៧/៥៨០ ស្តីពីការប្រោសព្រះរាជទាន ប្រគេនចំពោះព្រះតេជគុណ **ស៊ាង ឈាង** នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ៥៣០៦

១៥-១១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១១០៧/៥៨១ ស្តីពីការប្រោសព្រះរាជទាន ចំពោះលោក និង អ្នកស្រី ជាជនបរទេស ចំនួន ០៣ រូប នូវគ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា ៥៣០៧

១៥-១១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១១០៧/៥៨២ ស្តីពីការប្រោសព្រះរាជទាន ចំពោះ Mr. DONG MINH TOAN នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ៥៣០៨

១៥-១១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១១០៧/៥៨៣ ស្តីពីការប្រោសព្រះរាជទាន ចំពោះលោកឧកញ៉ា **ហេង ឡុង** នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ៥៣០៩

II.រាជរដ្ឋាភិបាល

១.អនុក្រឹត្យ

១៥-១១-២០០៧ -អនុក្រឹត្យ លេខ ១៧៥ អនក្រ.បក ស្តីពីលក្ខន្តិកៈមន្ត្រីស្រាវជ្រាវ នៃរាជបណ្ឌិតសភាកម្ពុជា ៥៣១០

១៦-១១-២០០៧ -អនុក្រឹត្យលេខ ៥២១ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៥៣១៦

១៦-១១-២០០៧ -អនុក្រឹត្យលេខ ៥២២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៣១៨

១៦-១១-២០០៧ -អនុក្រឹត្យ លេខ ៥២៣ អនក្រ.តត ស្តីពីកាតែងតាំង ការផ្ទេរ និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៥៣១៩

១៦-១១-២០០៧ -អនុក្រឹត្យ លេខ ៥២៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៥៣២២

១៦-១១-២០០៧ -អនុក្រឹត្យ លេខ ៥២៥ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៥៣២៣

២-សេចក្តីសំរេច

១៦-១១-២០០៧ -សេចក្តីសំរេចលេខ ៦១ សសរ ស្តីពីការបង្កើតយន្តការប្រតិកម្មរហ័ស ៥៣២៥

១៧-១១-២០០៧ -សេចក្តីសំរេចលេខ ៦២ សសរ ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល ៥៣២៨

III-ការងារបណ្តាក្រសួង

១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សារាចរណែនាំ

១៤-១១-២០០៧ -សារាចរណែនាំ លេខ ០០៤ សហវ ស្តីពីការអនុវត្តន៍ពន្ធប៉ាតង់ ៥៣២៩

២-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

០៧-១១-២០០៧ -ប្រកាសលេខ ១១០៧ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន សាជីវកម្ម ឧស្សាហកម្ម ហ័ររ៉ស បង្កើតរោងចក្រ " កាត់ដេរសម្លៀកបំពាក់ " ដែលមានឈ្មោះថា " សាជីវកម្ម ឧស្សាហកម្ម ហ័ររ៉ស " ៥៣៣២

១៦-១១-២០០៧ -ប្រកាសលេខ ១១៤២ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន អេថុន បង្កើតរោងចក្រ " កាត់ដេរសម្លៀកបំពាក់ " ដែលមានឈ្មោះថា " អេថុន " ៥៣៣៤

១៦-១១-២០០៧ -ប្រកាសលេខ ១១៤៣ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន មីម៉ុក ហ្វើនីឈ័រ បង្កើតរោងចក្រ " ផលិតគ្រឿងសង្ហារឹមផ្ទះបាយ និងគ្រឿងសង្ហារឹមផ្សេងៗ " ដែលមានឈ្មោះថា " មីម៉ុក ហ្វើនីឈ័រ " ៥៣៣៦

៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២២-៣-២០០៧ -លិខិតបញ្ជាក់លេខ ១១៥៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេហ្វ អេស ជី (ខេមបូឌា)** ៥៣៣៨

២២-៣-២០០៧ -លិខិតបញ្ជាក់លេខ ១១៦០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហាយ ថេក ស្តាហ្វ** ៥៣៤០

២២-៣-២០០៧ -លិខិតបញ្ជាក់លេខ ១១៦១ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សាន រុងរឿង** ៩៣៤២

២២-៣-២០០៧ -លិខិតបញ្ជាក់លេខ ១១៦២ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ធី អិន អេ ខនស្ត្រាក់សិន អេន ដេខំរេសិន ខមភេនី** ៩៣៤៤

២២-៣-២០០៧ -លិខិតបញ្ជាក់លេខ ១១៦៦ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឡាយ ហុគ** ៩៣៤៦

២២-៣-២០០៧ -លិខិតបញ្ជាក់លេខ ១១៦៧ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេ អោយ ឃ្យូ (ខេមបូឌា) អ៊ីន** ៩៣៤៨

២២-៣-២០០៧ -លិខិតបញ្ជាក់លេខ ១១៧៣ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប៉ាស៊ីហ្វិក អូតែល** ៩៣៤៩

២២-៣-២០០៧ -លិខិតបញ្ជាក់លេខ ១១៧៤ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខ្មែរ ជ្រៃឃ្លាន អេនធើប្រាយ** ៩៣៥១

ព្រះរាជក្រឹត្យ

នស/រកត/១១០៧/៥៧៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងឯកឧត្តម ជា តារ៉ា ជាទីប្រឹក្សាឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ដោយមិនទទួលប្រាក់បៀវត្ស ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល. ០៧១១.៦០៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧

លេខៈ ៥៤៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៧

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស / រកត / ១១០៧ / ៥៧៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានគ្គមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍

ចំពោះ

១- លោកជំទាវ ប៊ុន រ៉ានី ហ៊ុន សែន
២- ព្រះអង្គម្ចាស់ក្សត្រី នរោត្តម ម៉ារី រណឫទ្ធិ
៣- ឯកឧត្តម ហួច ស៊ុនហួត

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល. ០៧៦១. ៦០៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧

លេខៈ ៥៤៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ខែ វិច្ឆិកា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១១០៧/៥៨០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ប្រគេនចំពោះ

ព្រះតេជគុណ ស៊ាង ឈាង

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៧១១.៦០៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧

លេខៈ ៥៣៧ ច.ល
ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ២០០៧
អគ្គលេខាធិការគណៈរាជរដ្ឋាភិបាល

ស៊ុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១១០៧/៥៨១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្នត្តយាធិបតី ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

១- លោក Kim Tae-Yeon
២- លោក Kim Myung-Il
៣- អ្នកស្រី Lee Jae-Sook

នូវ

គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៧១១.៦១០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧

លេខ:៥៤៦ ច.ល
[illegible]
[illegible] ថ្ងៃទី [illegible] ខែ វិច្ឆិកា ឆ្នាំ២០០៧
[illegible]រដ្ឋាភិបាល

ព្រះរាជក្រឹត្យ

នស/រកត/១១០៧/៥៨២

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

Mr. DONG MINH TOAN

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល.០៧១១.៦១១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧

លេខ:៥៤៧ ច.ល
ថតចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧
[illegible] រាជរដ្ឋាភិបាល
[illegible] ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១១០៧/៥៨៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

លោកឧកញ៉ា ហេង ឡុង

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៩៧.០៧១១.៦១២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧

លេខៈ ៤៤៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ជិនកេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៣៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

លក្ខន្តិកៈមន្ត្រីស្រាវជ្រាវនៃរាជបណ្ឌិតសភាកម្ពុជា

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមិនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា ៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យ លេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពី ការបង្កើតរាជបណ្ឌិតសភាកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៧/៣១០ ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០០៧ ស្តីពីប្រាក់បំណាច់ស្រាវជ្រាវរបស់សមាជិកបណ្ឌិតសភា និងមន្ត្រីស្រាវជ្រាវនៃរាជបណ្ឌិតសភាកម្ពុជា

-បានឃើញអនុក្រឹត្យលេខ ៤៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០០ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់រាជបណ្ឌិតសភាកម្ពុជា

-យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១ .-

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីលក្ខណៈសម្បត្តិ មុខងារ ភារកិច្ច និងសិទ្ធិ របស់មន្ត្រីស្រាវជ្រាវនៃរាជបណ្ឌិតសភាកម្ពុជា។

មាត្រា ២ .-

អនុក្រឹត្យនេះអនុវត្តចំពោះមន្ត្រីស្រាវជ្រាវជាមន្ត្រីមុខងារសាធារណៈ ក្របខណ្ឌប្រភេទ ក ដែលមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រជាន់ខ្ពស់ឡើងទៅ ហើយកំពុងបំពេញមុខងារស្រាវជ្រាវនៅរាជបណ្ឌិតសភាកម្ពុជា នៃទីស្តីការគណៈរដ្ឋមន្ត្រី។

ជំពូកទី ២

លក្ខខណ្ឌ និងលក្ខណៈសម្បត្តិនៃមន្ត្រីស្រាវជ្រាវ

មាត្រា ៣ .-

មន្ត្រីស្រាវជ្រាវជាមន្ត្រីដែលមានឧបនិស្ស័យជាអ្នកសិក្សាស្រាវជ្រាវ ទៅតាមមុខជំនាញរបស់ខ្លួន នៅគ្រប់ផ្នែកនៃរាជបណ្ឌិតសភាកម្ពុជា។

មាត្រា ៤ .-

លក្ខណៈសម្បត្តិចូលជាមន្ត្រីស្រាវជ្រាវ នៃរាជបណ្ឌិតសភាកម្ពុជាមានដូចខាងក្រោម ៖

១- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រជាន់ខ្ពស់ឡើងទៅ

២- កំពុងបំពេញការងារស្រាវជ្រាវតាមផែនការ

៣- មានលទ្ធផលស្រាវជ្រាវតាមផែនការ

៤- មានប្រវត្តិការងារល្អ

៥- មានសីលធម៌រស់នៅល្អ

លក្ខណៈសម្បត្តិផ្សេងៗទៀតនឹងត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់មន្ត្រីស្រាវជ្រាវ ។

មាត្រា ៥ .-

លក្ខណៈសម្បត្តិជាមន្ត្រីស្រាវជ្រាវម្នាក់ៗ ត្រូវបានវាយតម្លៃដោយគណៈគ្រប់គ្រងវិទ្យាស្ថាន និងដោយក្រុមសមាជិកពេញសិទ្ធិនៃរាជបណ្ឌិតសភាកម្ពុជា ហើយត្រូវទទួលស្គាល់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តាមសំណើរបស់គណៈកម្មាធិការប្រតិបត្តិនៃរាជបណ្ឌិតសភាកម្ពុជា ។

មាត្រា ៦ .-

ក្រោយពេលចូលជាមន្ត្រីស្រាវជ្រាវហើយ មន្ត្រីស្រាវជ្រាវម្នាក់ៗត្រូវបំពេញលក្ខខណ្ឌ ដើម្បីរក្សាស្ថានភាពរបស់ខ្លួនដូចខាងក្រោម ៖

១- អនុវត្តការស្រាវជ្រាវរបស់ខ្លួន តាមផែនការដែលបានកំណត់

២- មានលទ្ធផលស្រាវជ្រាវ តាមផែនការដែលបានកំណត់

៣- ចូលរួមប្រជុំទៀងទាត់ក្នុងការងារស្រាវជ្រាវ តាមផ្នែកជំនាញរបស់ខ្លួន

៤- មានសីលធម៌វិជ្ជាជីវៈជាអ្នកស្រាវជ្រាវ ។

មាត្រា ៧ .-

លក្ខណៈសម្បត្តិជាមន្ត្រីស្រាវជ្រាវអាចត្រូវបញ្ចប់វិញបាន ទៅតាមករណីជាក់ស្តែង ផ្អែកលើការវាយតម្លៃរបស់គណៈគ្រប់គ្រងវិទ្យាស្ថាន និងរបស់ក្រុមសមាជិកពេញសិទ្ធិ នៃរាជបណ្ឌិតសភាកម្ពុជា ។

បែបបទនៃការវាយតម្លៃ និងការបញ្ចប់លក្ខណៈសម្បត្តិជាមន្ត្រីស្រាវជ្រាវ និងការវាយតម្លៃស្នាដៃស្រាវជ្រាវ មានកំណត់នៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់មន្ត្រីស្រាវជ្រាវ ។

មាត្រា ៨ .-

ក្រុមសមាជិកពេញសិទ្ធិនៃរាជបណ្ឌិតសភាកម្ពុជា ធ្វើការវាយតម្លៃលក្ខណៈសម្បត្តិមន្ត្រីស្រាវជ្រាវ ក្នុងផែនការដែលបានកំណត់រៀងរាល់ ៦ខែម្តង ។

មាត្រា ៩ .-

មន្ត្រីដែលត្រូវបានបញ្ចប់លក្ខណៈសម្បត្តិជាមន្ត្រីស្រាវជ្រាវ ត្រូវអស់សិទ្ធិក្នុងការទទួលប្រាក់បំណាច់ស្រាវជ្រាវ ចាប់ពីកាលបរិច្ឆេទចេញប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តាមសំណើរបស់គណៈកម្មាធិការប្រតិបត្តិនៃរាជបណ្ឌិតសភាកម្ពុជា ។

រយៈពេលចេញប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវកំណត់យ៉ាងយូរ ១ខែ បន្ទាប់ពីរបាយការណ៍វាយតម្លៃរបស់ក្រុមសមាជិកពេញសិទ្ធិនៃរាជបណ្ឌិតសភាកម្ពុជា ។

ជំពូកទី ៣
មុខងារ និងភារកិច្ចរបស់មន្ត្រីស្រាវជ្រាវ

មាត្រា ១០ ._

មន្ត្រីស្រាវជ្រាវមានមុខងារចូលរួមចំណែកអភិវឌ្ឍប្រទេសជាតិ ក្នុងវិស័យស្រាវជ្រាវវប្បធម៌ និងវិទ្យាសាស្ត្រ តាមរយៈកម្លាំងបញ្ញាញាណរបស់ខ្លួន ដើម្បីក្លាយទៅជាធនធានមនុស្សដែលមានសមត្ថភាពក្នុងមុខជំនាញ នៅពេលបច្ចុប្បន្ន និងទៅអនាគត។

មាត្រា ១១ ._

ភារកិច្ចរបស់មន្ត្រីស្រាវជ្រាវ ៖

១- អនុវត្តការសិក្សាស្រាវជ្រាវ ដើម្បីបង្កើតស្នាដៃរួម និងផ្ទាល់ខ្លួន

២- អនុវត្តផែនការការងារ ដោយស្មារតីទទួលខុសត្រូវខ្ពស់ និងមានគំនិតផ្តួចផ្តើមក្នុងវិស័យស្រាវជ្រាវ

៣- ចូលរួមប្រជុំតាមផ្នែកជំនាញ ចូលរួមក្នុងសិក្ខាសាលា សន្និសីទ គម្រោងស្រាវជ្រាវជាតិ និងអន្តរជាតិ

៤- ចូលរួមក្នុងសកម្មភាពបង្រៀន និងការផ្លាស់ប្តូរបទពិសោធន៍

៥- ចូលរួមក្នុងការរៀបចំគម្រោងផែនការស្រាវជ្រាវ

៦- ចូលរួមក្នុងការពិភាក្សា វាយតម្លៃលទ្ធផលនៃការស្រាវជ្រាវ

៧- សហការ បើកទូលាយក្នុងកិច្ចការស្រាវជ្រាវ

៨- ទទួលខុសត្រូវចំពោះលទ្ធផលស្រាវជ្រាវ ដែលកំពុងធ្វើការស្រាវជ្រាវ និងដែលពុំទាន់ធ្វើការផ្សព្វផ្សាយ។

ស្នាដៃស្រាវជ្រាវ ការចូលរួមប្រជុំក្នុងការងារស្រាវជ្រាវវប្បធម៌ និងវិទ្យាសាស្ត្រផ្សេងៗ ជាលក្ខខណ្ឌចាំបាច់សម្រាប់មន្ត្រីស្រាវជ្រាវម្នាក់ៗ។

មាត្រា ១២ ._

ផ្នែកជំនាញនីមួយៗនៃរាជបណ្ឌិតសភាកម្ពុជា មានភារកិច្ចទទួលខុសត្រូវអំពីការបង្កើតស្នាដៃ ការវាយតម្លៃស្នាដៃ ការចូលរួមប្រជុំ ក្នុងការងារស្រាវជ្រាវវប្បធម៌ និងវិទ្យាសាស្ត្រ របស់មន្ត្រីស្រាវជ្រាវម្នាក់ៗ ដើម្បីធានានូវលក្ខណៈសម្បត្តិជាមន្ត្រីស្រាវជ្រាវ និងសិទ្ធិផ្សេងៗរបស់មន្ត្រីស្រាវជ្រាវ។

ជំពូកទី ៤
សិទ្ធិរបស់មន្ត្រីស្រាវជ្រាវ

មាត្រា ១៣ ._

មន្ត្រីស្រាវជ្រាវដែលទទួលស្គាល់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវបានទទួលនូវប្រាក់បំណាច់ស្រាវជ្រាវ ដូចមានកំណត់នៅក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៧០៧/៣១០ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីប្រាក់បំណាច់ស្រាវជ្រាវរបស់សមាជិកបណ្ឌិតសភា និងមន្ត្រីស្រាវជ្រាវ នៃរាជបណ្ឌិតសភាកម្ពុជា។

មាត្រា ១៤ .-

លទ្ធផលនៃការស្រាវជ្រាវត្រូវយកធ្វើជាមូលដ្ឋានសម្រាប់ការតម្លើងថ្នាក់ ឬឋានន្តរស័ក្តិ ក្នុងការផ្តល់គ្រឿងឥស្សរិយយស និងការតម្លើងកម្រិតប្រាក់បំណាច់ស្រាវជ្រាវរបស់មន្ត្រីស្រាវជ្រាវ តាមនីតិវិធីជាធរមានក្នុងមុខងារសាធារណៈ។

លទ្ធផលនៃការស្រាវជ្រាវរបស់មន្ត្រីស្រាវជ្រាវដែលស្ថិតក្នុងផែនការរបស់រាជបណ្ឌិតសភាកម្ពុជា ជាកម្មសិទ្ធិរបស់រដ្ឋ ប៉ុន្តែមន្ត្រីស្រាវជ្រាវអាចទទួលបាននូវកម្រៃកម្មសិទ្ធិបញ្ញាពីស្នាដៃរបស់ខ្លួន។

មាត្រា ១៥ .-

ការស្រាវជ្រាវត្រូវបានទទួលការគាំពារពីរដ្ឋក្នុងការការពារកម្មសិទ្ធិបញ្ញា ការបោះពុម្ពផ្សាយ ការចូលទៅកាន់កន្លែងដែលជាកម្មវត្ថុនៃការស្រាវជ្រាវ ការការពារផ្នែកសន្តិសុខ និងសុវត្ថិភាពរបស់មន្ត្រីស្រាវជ្រាវ និងការផ្តល់នៃធានសម្រាប់ការស្រាវជ្រាវ។

មាត្រា ១៦ .-

មន្ត្រីស្រាវជ្រាវត្រូវបានផ្តល់អាទិភាព ក្នុងការបណ្តុះបណ្តាលនៅក្នុង និងក្រៅប្រទេស ផ្អែកលើលក្ខណៈសម្បត្តិខាងការស្រាវជ្រាវរបស់ខ្លួន និងលក្ខខណ្ឌចាំបាច់ដែលបានបំពេញ។

ជំពូកទី ៥

អន្តរប្បញ្ញត្តិ

មាត្រា ១៧ .-

ចាប់ពីពេលអនុក្រឹត្យនេះចូលជាធរមាន ក្នុងរយៈពេលយ៉ាងយូរ ២ខែ មន្ត្រីរាជការកំពុងបម្រើការនៅរាជបណ្ឌិតសភាកម្ពុជា ដែលមានសញ្ញាបត្របណ្ឌិត និងបរិញ្ញាបត្រជាន់ខ្ពស់ អាចដាក់ពាក្យសុំចូលជាមន្ត្រីស្រាវជ្រាវបណ្តោះអាសន្ន។

មន្ត្រីដែលចូលជាមន្ត្រីស្រាវជ្រាវបណ្តោះអាសន្ន ហើយទទួលស្គាល់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី មានសិទ្ធិទទួលប្រាក់បំណាច់ស្រាវជ្រាវ កម្រិត៥។ ក្នុងរយៈពេល ១២ខែ យ៉ាងយូរក្រុមសមាជិកពេញសិទ្ធិនៃរាជបណ្ឌិតសភាកម្ពុជា ត្រូវធ្វើការវាយតម្លៃមន្ត្រីដែលមានលក្ខណៈសម្បត្តិ ដូចមានកំណត់ក្នុងមាត្រា៤ ដើម្បីចូលជាមន្ត្រីស្រាវជ្រាវ។

ជំពូកទី ៦

អវសានប្បញ្ញត្តិ

មាត្រា ១៨ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍។

មាត្រា ១៩.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងប្រធានរាជបណ្ឌិតសភាកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ២០០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សុខ អាន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១៩
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩៧១ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយសហមេត្រី
រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

ស ម្រេ ច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយសហមេត្រី** តាមលំដាប់ថ្នាក់ចំនួន ០៦ គ្រឿង ជូននាយទាហាននៃកងទ័ពជើងគោក ឥណ្ឌូនេស៊ី ដែលមានស្នាដៃល្អក្នុងការលើកស្ទួយ ទំនាក់ទំនងមិត្តភាព និង កិច្ចសហប្រតិបត្តិការរវាងកងទ័ពជើងគោក ឥណ្ឌូនេស៊ី និង កងយោធពលខេមរភូមិន្ទ នៃព្រះរាជាណាចក្រកម្ពុជា ដូចមានរាយនាមខាងក្រោម ÷

ក.មេដាយសហមេត្រីថ្នាក់ ធិបឌិន្ទ

- ឯកឧត្តម នាយឧត្តមសេនីយ៍ **ឌី ស៊ូកូ សាន់តូសូ** (D.joko.Santoso) មេបញ្ជាការកងទ័ពជើងគោក ឥណ្ឌូនេស៊ី

ខ.មេដាយសហមេត្រីថ្នាក់ សេនា

១-ឧត្តមសេនីយ៍ឯក **តូនណូ ស៊ូរ៉ាហ្មាន់** (LTG. Tono Surahman) ជំនួយការសន្តិសុខ មេបញ្ជាការកងទ័ពជើងគោក

២-ឧត្តមសេនីយ៍ទោ **អ៊ីវ៉ាន់ រីដវ៉ាន់ ស៊ុឡាន់ចាណា** (MG. Iwan Ridwan Sulanjana) ជំនួយការប្រតិបត្តិការ មេបញ្ជាការកងទ័ពជើងគោក

៣-ឧត្តមសេនីយ៍ទោ **ស៊ុណាគូ** (MG.Sunarko) មេបញ្ជាការកងកំលាំងពិសេស

គ-មេដាយសហមេត្រីថ្នាក់ អស្សឫទ្ធិ

១-វរសេនីយ៍ឯក **សូនី** (Col. Sonny) លេខាធិការផ្ទាល់ មេបញ្ជាការកងទ័ពជើង

២-វរសេនីយ៍ឯក **ស៊ុដាម៉ូ** (Col. Sudarmo) នាយទាហានទំនាក់ទំនងអន្តរជាតិ

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រី ក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ ទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែ

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ...៩៧៤..អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តតាកែវ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០៥ រូប ដែលបានឧបត្ថម្ភថវិកា ជួយកសាង ប៉ុស្តិ៍សុខភាព សាលារៀន ផ្លូវលំផ្លូវ ស្ពាន លូ និងសមិទ្ធផល ផ្នែកព្រះពុទ្ធសាសនា នៅឃុំពោធិ៍រំចាក ស្រុកព្រៃកប្បាស ខេត្តតាកែវ ដូចមានរាយនាមខាងក្រោម :-

១-លោក	NAKAMURA KANJI	នៅប្រទេស ជប៉ុន	ថវិកា ចំនួន ១០.០០០ ដុល្លារ
២-លោក	Dr.NAKADA EIZOU	នៅប្រទេស ជប៉ុន	ថវិកា ចំនួន ១០.០០០ ដុល្លារ
៣-អ្នកស្រី	NARUSE SHINOBU	នៅប្រទេស ជប៉ុន	ថវិកា ចំនួន ១៣.៥០០ ដុល្លារ
៤-លោក	អេង សំអុល	នៅខេត្តតាកែវ	ថវិកា ចំនួន ១៥.០០០ ដុល្លារ
៥-លោក	ឈុន សុភមង្គល	នៅខេត្តតាកែវ	ថវិកា ចំនួន ១០.៥០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៥៧៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតែងតាំង ការផ្ទេរ និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រង ការអនុវត្តន៍ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងមន្ត្រីរាជការ នៃក្រសួងពាណិជ្ជកម្ម ដូចមានរាយនាមខាងក្រោម ៖

១. លោក សុខ សារឥល	វរមន្ត្រីថ្នាក់លេខ ៣ ជាអគ្គាធិការរង នៃអគ្គាធិការដ្ឋាន
២. លោក ស៊ុន តារា	វរមន្ត្រីថ្នាក់លេខ ៤ ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ

៣. លោក ស៊ូ សាឡៃ វរមន្ត្រីថ្នាក់លេខ ៩ ជាអគ្គាធិការរង នៃអគ្គាធិការដ្ឋាន
៤. លោក លឹម មិនចំនួ វរមន្ត្រីថ្នាក់លេខ ៩ ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
៥. លោក ស៊ាន ថៃ វរមន្ត្រីថ្នាក់លេខ ១០ ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ

ប្រការ ២ : ត្រូវបានផ្ទេរភារកិច្ចមន្ត្រីរាជការ នៃក្រសួងពាណិជ្ជកម្ម ដូចមានរាយនាមខាងក្រោម ៖

១. លោក យី គិមសេង វរមន្ត្រីថ្នាក់លេខ ៣ ពីអគ្គាធិការរង ទៅជាអគ្គនាយករង នៃអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស
២. លោក លី ផាណ្ណា វរមន្ត្រីថ្នាក់លេខ ៥ ពីអគ្គនាយករងបច្ចេកទេស ទៅជាអគ្គនាយករង នៃអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស
៣. លោក ស៊ុម រ៉ា វរមន្ត្រីថ្នាក់លេខ ១០ ពីអគ្គនាយករងបច្ចេកទេស ទៅជាអគ្គនាយករង នៃអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស
៤. លោក ខៀត សុគិន វរមន្ត្រីថ្នាក់លេខ ៥ ពីប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ទៅជាប្រធាននាយកដ្ឋានរដ្ឋបាល
៥. លោក ជួន ទន វរមន្ត្រីថ្នាក់លេខ ៦ ពីប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស ទៅជាប្រធាននាយកដ្ឋានពាណិជ្ជកម្មទ្វេភាគី
៦. លោក ហូ សារ៉ាន់ វរមន្ត្រីថ្នាក់លេខ ៤ ពីប្រធាននាយកដ្ឋាននីតិកម្ម ទៅជាប្រធាននាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម

ប្រការ ៣ : ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីរាជការ នៃក្រសួងពាណិជ្ជកម្ម ដូចមានរាយនាមខាងក្រោម ៖

១. លោក អ៊ុន ម៉ុនថា អនុមន្ត្រីថ្នាក់លេខ ៤ ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
២. លោក ឆន ធីរៈ អនុមន្ត្រីថ្នាក់លេខ ៤ ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ
៣. លោក ហង្ស ម៉ើន អនុមន្ត្រីថ្នាក់លេខ ៦ ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស
៤. លោក ឡឹក តារារិទ្ធ អនុមន្ត្រីថ្នាក់លេខ ៩ ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ
៥. លោក ខៀត ខ្លឹង អនុមន្ត្រីថ្នាក់លេខ ៣ ជាអធិការ នៃអគ្គាធិការដ្ឋាន
៦. លោក រាម តាច អនុមន្ត្រីថ្នាក់លេខ ៤ ជាអធិការ នៃអគ្គាធិការដ្ឋាន
៧. លោក តាំង សុជាតិ អនុមន្ត្រីថ្នាក់លេខ ៥ ជាប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ
៨. លោក មុំ ចន្ទតារ៉ា អនុមន្ត្រីថ្នាក់លេខ ៧ ជាប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង
៩. លោក អ៊ុច គីមយ៉ុន អនុមន្ត្រីថ្នាក់លេខ ៧ ជាប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
១០. លោក ស៊ីន សុថា អនុមន្ត្រីថ្នាក់លេខ ៨ ជាប្រធាននាយកដ្ឋានជំរុញពាណិជ្ជកម្ម
១១. លោក ម៉ែន សុទិដ្ឋជាតិ អនុមន្ត្រីថ្នាក់លេខ ៩ ជាប្រធាននាយកដ្ឋានផ្តល់ព័ត៌មាន និងផ្ទៀងផ្ទាត់ច្បាប់
១២. លោក សាន តិរុណ្ណា អនុមន្ត្រីថ្នាក់លេខ ១១ ជាប្រធាននាយកដ្ឋានពាណិជ្ជកម្ម ពហុភាគី
១៣. លោក ទ្រឹម តារាឫទ្ធិ អនុមន្ត្រីថ្នាក់លេខ ១២ ជាប្រធាននាយកដ្ឋាននីតិកម្ម

មាត្រា ៤ : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៤៥ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមតម្រូវការការងារចាំបាច់

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងលោក ម៉ូវ៉ា ភាធី ជាសមាជិកក្រុមលេខាសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អគ្គនាយករង បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

អគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៧៤៥ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្ប ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ : នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យ ច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានឃើញអនុក្រឹត្យលេខ : ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និង ការប្រព្រឹ ទៅរបស់ក្រសួង ស្ថាប័ន និង រដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ : ១៣ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹ ទៅរបស់ក្រសួងធម្មការ និងសាសនា
- អនុក្រឹត្យលេខ : ៨៨ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ២០០៦ ស្តីពីការបង្កើតអគ្គាធិការដ្ឋ ពុទ្ធិកសិក្សាជាតិ នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ នៃព្រះរាជាណាចក្រកម្ពុជា

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងមន្ត្រីរាជការ នៃអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិចំនួន ០៦ រូប ដូចមានរាយនាមខាងក្រោម

១- លោក ម៉ែន ប្រាជ្ញ ជាទីប្រឹក្សាអមអគ្គាធិការដ្ឋានពុទ្ធិកសិក្សាឋានៈស្មើប្រធាននាយកដ្ឋាន

២- លោក អ៊ុច សួរ ជាទីប្រឹក្សាអមអគ្គាធិការដ្ឋានពុទ្ធិកសិក្សាឋានៈស្មើប្រធាននាយកដ្ឋាន

៣- លោក រិត ខេមរារស្មី ជាទីប្រឹក្សាអមអគ្គាធិការដ្ឋានពុទ្ធិកសិក្សាឋានៈស្មើប្រធាននាយកដ្ឋាន

៤- លោក ទើ ហុងសាន ជាទីប្រឹក្សាអមអគ្គាធិការដ្ឋានពុទ្ធិកសិក្សាឋានៈស្មើប្រធាននាយកដ្ឋាន

៥- លោក ប្រាក់ ឡើ ជាទីប្រឹក្សាអមអគ្គាធិការដ្ឋានពុទ្ធិកសិក្សាឋានៈស្មើប្រធាននាយកដ្ឋាន

៦- លោក ខេត ផុន ជាទីប្រឹក្សាអមអគ្គាធិការដ្ឋានពុទ្ធិកសិក្សាឋានៈស្មើប្រធាននាយកដ្ឋា

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តតាម អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>**កន្លែងទទួល :**</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ...៦១...សសរ...

សេចក្តីសម្រេច

ស្តីពី

ការបង្កើតយន្តការប្រតិកម្មរហ័ស

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់

សម្រេច

ប្រការ ១: ត្រូវបានបង្កើតយន្តការសម្រាប់ធ្វើប្រតិកម្មរហ័ស ចំពោះមតិអវិជ្ជមានរបស់មជ្ឈដ្ឋាននានាមកលើរាជ-រដ្ឋាភិបាលកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម ជុំ ម៉ុនរ៉ុខ	ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី	ប្រធាន
២-ឯកឧត្តម ផៃ ស៊ីផាន	សមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌	អនុប្រធាន
៣-ឯកឧត្តម ម៉ល់ ធឿន	ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី	សមាជិក
៤-ឯកឧត្តម យូ ស៊ុនឡុង	ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី	សមាជិក
៥-ឯកឧត្តម សៅ សុខា	មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស	សមាជិក

៦-ឯកឧត្តម ជុំ ចាន់	មេបញ្ជាការរងកងទ័ពជើងគោក	សមាជិក
៧-ឯកឧត្តម សុខ ផល	អគ្គស្នងការរងនគរបាលជាតិ	សមាជិក
៨-ឯកឧត្តម ម៉ាណំ ច័ន្ទតារា	មេធាវីរាជរដ្ឋាភិបាល	សមាជិក
៩-ឯកឧត្តម ជីវ សុខចាន់	សមាជិកក្រុមប្រឹក្សាអ្នកច្បាប់	សមាជិក
១០-ឯកឧត្តម ស៊ាន ប៊ូរិត	ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី	សមាជិក
១១-ឯកឧត្តម ម៉ៅ អាយុទ្ធ	ប្រធានសមាគមទូរទស្សន៍ជាតិកម្ពុជា	សមាជិក
១២-ឯកឧត្តម អ៊ិន ធីរៈជាតិ	ប្រធានសមាគមគ្រឹះស្ថានឧត្តមសិក្សា	សមាជិក
១៣-ឯកឧត្តម ម៉ួន លឹមហេង	ប្រធាននាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច	សមាជិក
១៤-លោក ជា សំអាង	អនុប្រធានរដ្ឋបាលព្រៃឈើ	សមាជិក
១៥-លោក ឡុង ឈាង	អនុប្រធានរដ្ឋបាលជលផល	សមាជិក
១៦-លោក ស្នួន ស៊ីផាត	ប្រធានលេខាធិការដ្ឋានគណៈកម្មការ សុរិយោដីជាតិ	សមាជិក
១៧-លោកស្រី អ៊ុក ស៊ីហាវ	អនុប្រធាននាយកដ្ឋានអភិរក្សធនធានធម្មជាតិ ក្រសួងបរិស្ថាន	សមាជិក
១៨-លោក សោម អូន	ជំនួយការអមទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកការងារសហជីព	សមាជិក
១៩-លោក ចៅ ទាសនា	ជំនួយការអមទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកការងារអង្គការមិនមែនរដ្ឋាភិបាល	សមាជិក
២០-លោក សេង សាខន	ប្រធាននាយកដ្ឋានព័ត៌មាន	សមាជិក
២១-នាយក នាយិកាខុទ្ទកាល័យគ្រប់គ្រសួង រដ្ឋលេខាធិការដ្ឋាន		សមាជិក

ប្រការ ២: យន្តការនេះមានភារកិច្ច ដូចតទៅ :

-សិក្សា និងទប់ស្កាត់មតិអវិជ្ជមានទាំងឡាយដែលអាចកើតឡើងចំពោះរាជរដ្ឋាភិបាល ដោយធ្វើការផ្សព្វផ្សាយព័ត៌មានពិតជាមុន ជូនសាធារណមតិជាតិ និងអន្តរជាតិ

-ផ្សព្វផ្សាយព័ត៌មានដែលពាក់ព័ន្ធនឹងបញ្ហារសើប

-រៀបចំឯកសារបកស្រាយពន្យល់ និងឆ្លើយបំភ្លឺចំពោះមតិអវិជ្ជមានដែលមជ្ឈដ្ឋានក្នុង និងក្រៅប្រទេសបានចេញផ្សាយ

-សិក្សាតាមផ្លូវច្បាប់ ចំពោះការផ្សព្វផ្សាយព័ត៌មានមិនពិត

-រាយការណ៍ពីលទ្ធផលសិក្សា លើកវិធានការ និងសុំការសម្រេចពីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

មុនចាត់វិធានការដូចរៀបរាប់ខាងលើ។

ប្រការ ៣: យន្តការនេះ មានលេខាធិការដ្ឋានអចិន្ត្រៃយ៍នៅទីស្តីការគណៈរដ្ឋមន្ត្រី។ លេខាធិការដ្ឋាននេះ ដឹកនាំដោយ ឯកឧត្តម ស៊ុខ សាធ ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី។

ប្រការ ៤: សមាជិកនៃយន្តការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

យន្តការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ហើយចំណាយក្នុងដំណើរការការងារជាបន្ទុកថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

ប្រការ ៥: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- -ដូចប្រការ ៥
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៥៦.ស.ស.រ

សេចក្តីសំរេច
ស្តីពីការផ្ទេរសិទ្ធិការទាររបស់រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការប្រក្រតីនៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

សំរេច

ប្រការ ១ : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវអញ្ជើញទៅចូលរួមកិច្ចប្រជុំកំពូលអាស៊ានលើកទី ១៣ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធនានា ចាប់ពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៧ នៅសាធារណរដ្ឋសិង្ហបុរី រហូតដល់ពេលសម្តេចនាយករដ្ឋមន្ត្រីអញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង និងឯកឧត្តម ស ខេង ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី [illegible] ខែ វិច្ឆិកា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ ២
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ០០៤......សហវ.....

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧

លិខិតចូល
ថ្ងៃទី ១៥ ខែ ១១ ឆ្នាំ 2007

សារាចរណែនាំ
ស្តីពី
ការអនុវត្តន៍ពន្ធប៉ាតង់

អនុលោមតាមខ្លឹមសារក្រឹត្យច្បាប់លេខ ២២ ក្រ.ច ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ១៩៨៥ ស្តីពីពន្ធប៉ាតង់ និងមាត្រា ៣៩ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១១ន.ស.៩៤ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងបទប្បញ្ញត្តិស្តីពីសារពើពន្ធ ដើម្បីសំរួលដល់ការគ្រប់គ្រងរបស់រដ្ឋបាលសារពើពន្ធ ក៏ដូចជាការបំពេញបន្ថែមការយល់ដឹងរបស់អ្នកជាប់ពន្ធក្នុងគោលបំណងបង្កើនចំណូលពន្ធ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមធ្វើការណែនាំដូចខាងក្រោម:

១- ពន្ធប៉ាតង់ជាពន្ធប្រចាំឆ្នាំ (១ឆ្នាំប្រមូល១ដង) ត្រូវចាប់ផ្តើមប្រមូល និងប្រមូលឱ្យអស់ នៅដើមឆ្នាំ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ៣១ ខែ មីនា នៃឆ្នាំនីមួយៗ ។ ពន្ធប៉ាតង់ ត្រូវបង់នៅរដ្ឋបាលសារពើពន្ធដែលអ្នកជាប់ពន្ធមានទីកន្លែងប្រកបអាជីវកម្មពិតប្រាកដ ។

២- អាជីវកម្មដ្ឋាន ដែលប្រកបមុខរបរច្រើនប្រភេទ ត្រូវបង់ពន្ធប៉ាតង់ផ្សេងៗគ្នា ទៅតាមប្រភេទមុខរបរនីមួយៗ ។ ប័ណ្ណប៉ាតង់មួយ សំរាប់មុខរបរមួយ ។

៣- អាជីវកម្មដ្ឋាន ដែលមានសាខានៅតាមខេត្ត-ក្រុងតែមួយ ដែលរួមគ្នាលក់ដូរ ឬផលិតមុខទំនិញដូចគ្នា មិនចាំបាច់បង់ពន្ធប៉ាតង់ផ្សេងគ្នាទេ។ ប្រសិនបើអាជីវកម្មដ្ឋាន ដែលមានសាខានៅតាមខេត្ត-ក្រុងផ្សេងគ្នា ត្រូវបង់ពន្ធប៉ាតង់ នៅខេត្ត-ក្រុងដែលសាខានោះស្ថិតនៅ ។

៤- ប័ណ្ណប៉ាតង់មានតំលៃតែចំពោះអ្នកដែលមានឈ្មោះក្នុងប័ណ្ណប៉ាតង់តែប៉ុណ្ណោះ ។ ករណីមានការផ្លាស់ប្តូរទីកន្លែងទៅខេត្ត-ក្រុងផ្សេង ឬ ផ្លាស់ប្តូរមុខរបរអាជីវកម្មថ្មី ត្រូវបង់ពន្ធប៉ាតង់ជាថ្មីម្តងទៀត ។

៥- អ្នកជាប់ពន្ធដែលចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬស្ទង់ថ្លៃ អាចប្រើប្រាស់នូវប័ណ្ណប៉ាតង់ដែលខ្លួនបានបង់ពន្ធរួចហើយ ដើម្បីបំពេញបែបបទចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬស្ទង់ថ្លៃ តែប័ណ្ណប៉ាតង់នោះត្រូវតែ

-ML

មានមុខរបរឱ្យស្របគ្នានឹងមុខរបរដែលត្រូវចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬស្នងថ្លៃ (ឧទាហរណ៍ : សាងសង់ លក់សំភារៈបរិក្ខារការិយាល័យ លក់គ្រឿងឧបភោគបរិភោគ រោងពុម្ព.........។ល។ ក្រោយពេលដេញថ្លៃ ពិគ្រោះថ្លៃ ឬស្នងថ្លៃបាន អ្នកជាប់ពន្ធត្រូវបង់ពន្ធប៉ាតង់ជាថ្មីផ្អែកតាមផលរបរដែលដេញថ្លៃ ពិគ្រោះថ្លៃ ឬស្នងថ្លៃបាននោះ នៅតាមសាខាពន្ធដារខេត្ត-ក្រុងដែលដេញថ្លៃ ពិគ្រោះថ្លៃ ឬស្នងថ្លៃបាន ដើម្បីអនុវត្តគំរោងរបស់ខ្លួន ÷

